ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:......០០១/១៧.........គ.ម.ក/ប្រ.ក.

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវការកែប្រែ

## វិធានប្រតិបត្តិការ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គមក. ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០២/១១ គមក.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611
E-mail : info@secc.gov.kh
Fax : 855-23-885-622

- បានឃើញប្រកាសលេខ ០០៥/១១ គមក.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ
- បានឃើញប្រកាសលេខ ០០៦/១១ គមក.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ
- បានឃើញប្រកាសលេខ ០០១/១២ ស្ទួន២ គមក.ប្រក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ០០១/១២ ស្ទួន៣ គមក.ប្រក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ០០១/១២ ស្ទួន៤ គមក.ប្រក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១
- យោងតាមសំណើសុំបន្ថែមវត្ថុជួញដូរមូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ-២០១២
- យោងតាមសំណើសុំបន្ថបញ្ចុះថ្លៃសេវាជួញដូរមូលបត្រ ថ្លៃសេវាជាត់ទាត់និងទូទាត់មូលបត្រ និងថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជាលើកទី២៦ នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣

## ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ ២ថ្មី ប្រការ ៥ថ្មី ប្រការ ៦ថ្មី ប្រការ ១០ថ្មី ប្រការ ១២ថ្មី ប្រការ ១៣ថ្មី និងប្រការ ១៧ថ្មី នៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ២ ប្រការ ៥ ប្រការ ៦ ប្រការ ១០ ប្រការ ១២ ប្រការ ១៣ និងប្រការ ១៧ នៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០៦/១១ គ.ម.ក./ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ។

**ប្រការ ២.-**

ដាក់ឱ្យអនុវត្តនូវប្រការ ២៤ថ្មី (មួយ) នៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ២៤ថ្មី នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០១/១២ ស្ទួន៣ គ.ម.ក./ប្រក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៣.-**

ដាក់ឱ្យអនុវត្តនូវប្រការ ១៤ថ្មី (មួយ) នៃវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ១៤ថ្មី នៃវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០១/១២ ស្ទួន២ គ.ម.ក./ប្រក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៤.-**

ដាក់ឱ្យអនុវត្តនូវប្រការ ១៣ថ្មី (មួយ) នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ១៣ថ្មី នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០១/១២ ស្ទួន៤ គ.ម.ក./ប្រក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៥.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៣

**គាត ឈន់**

**កន្លែងទទួល÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ..០០១.......

ចុះថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣

**ស្តីពី**

**ការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ**

**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

* * * * *

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ២ ថ្មី.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

-សមាជិក សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) ហើយជាសមាជិកនៃប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្ររបស់ ផ.ម.ក. និងមានសិទ្ធិប្រើប្រាស់នូវប្រព័ន្ធជួញដូរនិងប្រព័ន្ធកុំព្យូទ័រមួយចំនួនទៀតរបស់ ផ.ម.ក.។

-ការបញ្ជា សំដៅដល់ការបញ្ជាទិញ ឬលក់មូលបត្រដោយសមាជិក ដើម្បីធ្វើការជួញដូរមូលបត្រនៅ ផ.ម.ក.។

-ថ្ងៃបើក សំដៅដល់ថ្លៃជួញដូរដំបូងនៃមូលបត្រនៅក្នុង ផ.ម.ក. នៅថ្ងៃជួញដូរនីមួយៗ។

-ថ្លៃបិទ សំដៅដល់ថ្លៃជួញដូរចុងក្រោយនៃមូលបត្រដែលត្រូវបានកំណត់មុនពេលបិទម៉ោងជួញដូរនៅថ្ងៃជួញដូរនីមួយៗ រួមទាំងថ្លៃពិសេសផងដែរ។

-ថ្លៃពិសេស សំដៅដល់សំណើថ្លៃលក់ល្អបំផុត (Best Offer) ក្នុងករណីដែលថ្លៃលក់ទាបជាងថ្លៃមូលដ្ឋាន ឬសំណើថ្លៃទិញល្អបំផុត (Best Bid) ក្នុងករណីដែលថ្លៃទិញខ្ពស់ជាងថ្លៃមូលដ្ឋានសម្រាប់មូលបត្រដែលមិនត្រូវបានអនុវត្តការជួញដូររហូតដល់ម៉ោងបិទទីផ្សារ។

-ថ្លៃរំពឹងទុក (Expected Price) សំដៅដល់ថ្លៃអនុវត្តរំពឹងទុកដែលត្រូវផ្គូផ្គងឥតដាច់ក្នុងអំឡុងម៉ោងជួញដូរ ហើយត្រូវបានផ្សព្វផ្សាយជាសាធារណៈដល់វិនិយោគិនក្រោមទម្រង់ជាព័ត៌មាន។

-បរិមាណរំពឹងទុក (Expected Volume) សំដៅដល់បរិមាណសរុបនៃមូលបត្រកម្មសិទ្ធិដែលត្រូវផ្គូផ្គងលើមូលដ្ឋាននៃថ្លៃរំពឹងទុក។

-ប្រតិបត្តិការគណនីអតិថិជន សំដៅដល់ការទិញ ឬលក់មូលបត្រ បន្ទាប់ពីបានទទួលការបញ្ជាពីអតិថិជន។

-ប្រតិបត្តិការគណនីសមាជិក សំដៅដល់ការទិញ ឬលក់មូលបត្រ សម្រាប់គណនីផ្ទាល់របស់សមាជិក។

-ប្រព័ន្ធកុំព្យូទ័ររបស់ ផ.ម.ក. សំដៅដល់ប្រព័ន្ធកុំព្យូទ័រដែលប្រតិបត្តិដោយ ផ.ម.ក.ក្នុងគោលបំណងធ្វើជាអន្តរការីនៃការជួញដូរមូលបត្រ។

-ប្រព័ន្ធកុំព្យូទ័រសមាជិក សំដៅដល់ប្រព័ន្ធកុំព្យូទ័ររបស់សមាជិក ដែលត្រូវបានអនុញ្ញាតឱ្យបញ្ជូនការបញ្ជាទៅកាន់ប្រព័ន្ធកុំព្យូទ័ររបស់ ផ.ម.ក.។

-ការជួញដូរមិនប្រក្រតី សំដៅដល់ការជួញដូរទាំងឡាយ ដែលក្នុងនោះថ្លៃ ឬបរិមាណជួញដូរលើមូលបត្រមានការប្រែប្រួលខុសប្រក្រតីនៅក្នុងទីផ្សារ។

-ការជួញដូរមិនស្មោះត្រង់ សំដៅដល់ការជួញដូរដែលធ្វើឱ្យថ្លៃទីផ្សារមានការប្រែប្រួលដោយមធ្យោបាយមិនស្មោះត្រង់ដូចជាៈ ការប្រើប្រាស់ព័ត៌មានដែលមិនបានផ្សព្វផ្សាយ ការប្រើប្រាស់ព័ត៌មានផ្ទៃក្នុង ការប្រើឧបាយកលក្នុងទីផ្សារ ឬការផ្សព្វផ្សាយព័ត៌មានអំពីការដាក់ថ្លៃលើទីផ្សារ។

-ការត្រួតពិនិត្យទីផ្សារ សំដៅដល់ការឃ្លាំមើល និងវិភាគអំពីប្រតិបត្តិការមូលបត្រនៅលើទីផ្សារ ស្ថានភាពនៃបញ្ជា និងការដាក់ថ្លៃសម្រាប់ប្រតិបត្តិការទាំងនោះ ឬការប្រកាសព័ត៌មានដែលពាក់ព័ន្ធឯកសារផ្តល់ព័ត៌មាន ពាក្យចចាមអារ៉ាម និងរបាយការណ៍សារព័ត៌មានជាដើម។

**ប្រការ ៥ ថ្មី.- ការកែប្រែ ឬលុបចោលការបញ្ជាដែលបានបញ្ជូន**

សមាជិកអាចកែប្រែ ឬលុប ថ្លៃ ឬបរិមាណនៃបញ្ជាដែលបានដាក់។ ការកែប្រែ ឬលុបបញ្ជា អាចធ្វើបានតែចំពោះបញ្ជាដែលមិនទាន់ត្រូវបានអនុវត្តប៉ុណ្ណោះ។

## ជំពូកទី ២

## ផ្សារមូលបត្រកម្មសិទ្ធិ

**ប្រការ ៦ ថ្មី.- ម៉ោងជួញដូរ**

ម៉ោងជួញដូរត្រូវចាប់ផ្តើមពីម៉ោង ០៨:០០ ព្រឹក រហូតដល់ ១១:៣០ ព្រឹក។

ការអនុវត្តការជួញដូរត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ដងក្នុងមួយថ្ងៃ គឺនៅម៉ោង ០៩:០០ ព្រឹក ០៩:៣០ ព្រឹក ១០:០០ ព្រឹក ១០:៣០ ព្រឹក ១១:០០ ព្រឹក និង ១១:៣០ ព្រឹក។

**ប្រការ ១០ ថ្មី.- ឯកតាបញ្ជា ឯកតាគម្លាតថ្លៃ និងឯកតាជួញដូរ**

ឯកតាបញ្ជាគឺ ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

ឯកតាគម្លាតថ្លៃត្រូវកំណត់ដូចខាងក្រោម :

១-១០(ដប់) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃទាបជាង ៤.០០០(បួនពាន់)រៀល ក្នុង ០១(មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

២-២០ (ម្ភៃ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង៤.០០០ (បួនពាន់) រៀល ប៉ុន្តែទាបជាង ២០.០០០ (ពីរម៉ឺន) រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៣-៥០ (ហាសិប) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ២០.០០០ (ពីរម៉ឺន) រៀល ប៉ុន្តែទាបជាង ៤០.០០០ (បួនម៉ឺន) រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៤-១០០ (មួយរយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៤០.០០០ (បួនម៉ឺន) រៀល ប៉ុន្តែទាបជាង ១០០.០០០ (មួយសែន) រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៥-២០០ (ពីររយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ១០០.០០០ (មួយសែន) រៀល ប៉ុន្តែទាបជាង ២០០.០០០ (ពីរសែន) រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៦-៥០០ (ប្រាំរយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ២០០.០០០ (ពីរសែន) រៀល ប៉ុន្តែទាបជាង ៤០០.០០០ (បួនសែន) រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៧-១.០០០ (មួយពាន់) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៤០០.០០០ (បួនសែន) រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

ចំនួនឯកតាជួញដូរមូលបត្រកម្មសិទ្ធិអប្បបរមាក្នុងមួយប្រតិបត្តិការគឺ ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

## ប្រការ ១២ ថ្មី.- ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ

ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ គឺត្រូវស្មើនឹងទឹកប្រាក់ ដែលគណនាដោយ ±៥% (បូក ឬដក ប្រាំភាគរយ) នៃថ្លៃមូលដ្ឋាន ហើយទឹកប្រាក់ដែលទាបជាងឯកតាគម្លាតថ្លៃត្រូវបានកាត់ខ្ទង់ចេញ។ ក្នុងករណីថ្លៃមូលដ្ឋានទាបជាង ២០០ (ពីររយ) រៀល ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃគឺស្មើនឹង ១០ (ដប់) រៀល។

ទោះបីមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃមិនត្រូវបានកំណត់ទេ ចំពោះមូលបត្រកម្មសិទ្ធិដែលត្រូវដកចេញពីការចុះបញ្ជីលក់មូលបត្រ(Delisting) ហើយត្រូវបានអនុញ្ញាតឱ្យជួញដូរក្នុងអំឡុងពេលមួយកំណត់នៅមុនពេលដកចេញពីការចុះបញ្ជីលក់មូលបត្រ។

ទោះបីមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើ បន្ទាប់ពីមានការឯកភាពពីអគ្គនាយកនៃ គ.ម.ក. ផ.ម.ក. អាចកំណត់យកដែនកំណត់នៃបម្រែបម្រួលថ្លៃមូលដ្ឋានផ្សេងពីនេះ ក្នុងករណីដូចខាងក្រោម÷

១-ករណីដែលមូលបត្រមួយត្រូវបានចុះបញ្ជីឡើងវិញ។

២-ករណីដែលមូលបត្រមួយត្រូវបានចាប់ផ្តើមជួញដូរឡើងវិញ បន្ទាប់ពីត្រូវបានព្យួរអស់មួយរយៈពេលវែង។

៣-ករណីផ្សេងទៀតមានការលំបាកខ្លាំងក្នុងការអនុវត្តដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ។

## ប្រការ ១៣ ថ្មី.- គោលការណ៍ដេញថ្លៃ

រាល់ការជួញដូរត្រូវអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃតែមួយ (Single Price Auction)។

អាទិភាពនៃបញ្ជាទិញ និងបញ្ជាលក់ តាមរយៈវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ត្រូវកំណត់ទៅតាមគោលការណ៍ដូចខាងក្រោម៖

១-បញ្ជាលក់ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង ហើយបញ្ជាទិញដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

២-ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

ទោះបីជាមានចែងក្នុងកថាខណ្ឌទី ២ ក៏ដោយ អាទិភាពនៃបញ្ជាទិញនិងបញ្ជាលក់ ត្រូវបានកំណត់ដោយឡែក ក្នុងករណីនៃបញ្ជាព្រមពេលគ្នា:

១-ត្រូវបានចាត់ទុកថាជាបញ្ជាព្រមពេលគ្នា ចំពោះករណីដូចខាងក្រោម :

ក-រាល់បញ្ជាទិញដែលមានថ្លៃដែលត្រូវផ្គូផ្គងស្មើនឹងដែនកំណត់ថ្លៃខាងលើ(ថ្លៃមូលដ្ឋាន+៥%)។

ខ-រាល់បញ្ជាលក់ដែលមានថ្លៃដែលត្រូវផ្គូផ្គងស្មើនឹងដែនកំណត់ថ្លៃខាងក្រោម(ថ្លៃមូលដ្ឋាន-៥%)។

២-ចំពោះបញ្ជាព្រមពេលគ្នាដូចមានចែងនៅក្នុងចំណុច១ នៃកថាខណ្ឌនេះ បញ្ជាសម្រាប់គណនីអតិថិជន មានអាទិភាពលើបញ្ជាសម្រាប់គណនីសមាជិក។ ក្នុងករណីនេះ បញ្ជាដែលមានបរិមាណច្រើនជាង មានអាទិភាពលើបញ្ជាដែលមានបរិមាណតិចជាង។ ក្នុងករណីបញ្ជាមានបរិមាណស្មើគ្នា បញ្ជាដែល ផ.ម.ក. ទទួលបានមុនតាមរយៈប្រព័ន្ធជួញដូរត្រូវមានអាទិភាព។

៣-ការបែងចែងបរិមាណមូលបត្រសម្រាប់បញ្ជាព្រមពេលគ្នា ដូចមានចែងនៅក្នុងចំណុច១ នៃកថាខណ្ឌនេះ ត្រូវអនុវត្តតាមលំដាប់លំដោយអាទិភាព ដូចមានចែងក្នុងចំណុច២ នៃកថាខណ្ឌនេះ ដូចខាងក្រោម÷

ក-១០០ (មួយរយ) ដង នៃឯកតាជួញដូរ។

ខ-៥០០ (ប្រាំរយ) ដង នៃឯកតាជួញដូរ។

គ-១០០០ (មួយពាន់) ដង នៃឯកតាជួញដូរ។

ឃ-៥០ (ហាសិប)ភាគរយ នៃបរិមាណដែលនៅសល់។ ក្នុងករណីនេះ ប្រសិនបរិមាណនោះទាបជាងឯកតាជួញដូរ ត្រូវកំណត់យកត្រឹមឯកតាជួញដូរ។

ង-បរិមាណដែលនៅសល់ទាំងអស់ ត្រូវផ្តល់ឱ្យតាមអាទិភាព។

## ជំពូកទី ៣

## ការគ្រប់គ្រងទីផ្សារ

### ប្រការ ១៧ ថ្មី.- ការផ្សាយជាសាធារណៈនូវព័ត៌មានទីផ្សារ

ផ.ម.ក. ត្រូវផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យទីផ្សារដូចខាងក្រោម÷

១-ថ្លៃបើក និងថ្លៃបិទ។

២-បរិមាណ និងតម្លៃសរុបនៃការជួញដូរ។

៣-ថ្លៃរំពឹងទុក និងបរិមាណរំពឹងទុក។

ផ.ម.ក. អាចធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានផ្សេងទៀតដែលមានប្រយោជន៍សម្រាប់ការសម្រេចចិត្តវិនិយោគ ដើម្បីការពារផលប្រយោជន៍វិនិយោគិន។

## ជំពូកទី ៤

## ការត្រួតពិនិត្យការជួញដូរមូលបត្រ

### ប្រការ ២៤ ថ្មី (មួយ).- ថ្លៃសេវាជួញដូរមូលបត្រ

សមាជិកត្រូវបង់ថ្លៃសេវាប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងសេវាដែលបានផ្តល់ឱ្យស្របតាមវិធាននេះ។

របៀបគណនាប្រាក់ថ្លៃសេវាជួញដូរ អ្នកបង់ប្រាក់ និងពេលវេលាបង់ប្រាក់ ត្រូវបានកំណត់ដូចខាងក្រោមៈ

១-អត្រាៈ ប្រាក់ថ្លៃសេវាសម្រាប់ជួញដូរមូលបត្រកម្មសិទ្ធិ ត្រូវគណនាលើទឹកប្រាក់នៃការជួញដូរដែលបានទូទាត់ (ទឹកប្រាក់នៃប្រាក់កម្រៃដែលគណនា ត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស) តាមអត្រា ១៥/១០.០០០ ឬ ០,១៥ % (សូន្យក្បៀសដប់ប្រាំភាគរយ)។

២-អ្នកត្រូវបង់ប្រាក់ៈ ក្រុមហ៊ុនមូលបត្រដែលជាសមាជិករបស់ ផ.ម.ក.។

៣-ពេលវេលាបង់ប្រាក់ : ម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

សម្រាប់ឆ្នាំ ២០១៣ ថ្លៃសេវាសម្រាប់សេវាជួញដូរមូលបត្រកម្មសិទ្ធិដូចមានចែងក្នុងកថាខណ្ឌទី ២ ចំនុចទី ១ ខាងលើ ត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ៧,៥/១០.០០០ ឬ ០,០៧៥% (សូន្យក្បៀសសូន្យចិតសិបប្រាំភាគរយ)។

ឧបសម្ព័ន្ធប្រកាសលេខ.០០១..

ចុះថ្ងៃទី០៨ខែ កុម្ភៈ ឆ្នាំ ២០១៣

ស្តីពី

# ការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

**ប្រការ ១៤ ថ្មី (មួយ).- ថ្លៃសេវាជាត់ទាត់និងទូទាត់មូលបត្រ**

សមាជិកត្រូវបង់ថ្លៃសេវាជាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ តាមអត្រា និងពេលវេលាដូចខាងក្រោម÷

១-ថ្លៃសេវាសម្រាប់សេវាជាត់ទាត់និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ទឹកប្រាក់កម្រៃសេវាត្រូវកាត់កៀសមកត្រឹមមួយខ្ទង់) តាមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន) ឬ 0,0៥% (សូន្យក្បៀសសូន្យប្រាំភាគរយ)។

២-អ្នកបង់ថ្លៃសេវាគឺក្រុមហ៊ុនមូលបត្រដែលជាសមាជិកនៃប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ។

៣-ពេលវេលានៃការបង់ថ្លៃសេវាគឺ នៅម៉ោង៨:៣០ព្រឹកនៃកាលបរិច្ឆេទទូទាត់។

សម្រាប់ឆ្នាំ ២០១៣ ថ្លៃសេវាសម្រាប់ជាត់ទាត់និងទូទាត់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី១ ចំនុចទី១ ខាង-លើ ត្រូវកាត់បន្ថយចំនួន ៥0% មកត្រឹមអត្រា ២,៥/១០.000 (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ 0,0២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ)។

ឧបសម្ព័ន្ធប្រកាសលេខ.០០១...
ចុះថ្ងៃទី០៨ខែ កុម្ភៈ ឆ្នាំ ២០១៣
ស្តីពី
ការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
* * * * *

**ប្រការ ១៣ ថ្មី (មួយ).- ថ្លៃសេវាប្រតិបត្តិការរក្សាទុកមូលបត្រ**

សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃសេវារក្សាទុកមូលបត្រ ប្រាក់កម្រៃផ្ទេរវាងគណនីមូលបត្រ និងប្រាក់កម្រៃសេវាផ្សេងទៀតសម្រាប់សេវាដែលបានទទួល ស្របតាមប្រការនេះ។

សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃសេវាជូន ផ.ម.ក. ដូចខាងក្រោម÷

១-កម្រៃសេវារក្សាទុកមូលបត្រ÷ ជាកម្រៃសម្រាប់ការដាក់ផ្ញើមូលបត្រដែលស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ Initial Public Offerings (IPO)។ ប្រាក់កម្រៃសេវារក្សាទុកមូលបត្រប្រចាំខែ ត្រូវបង់នៅថ្ងៃទី១០ នៃខែបន្ទាប់ពីខែដែលប្រាក់កម្រៃនោះ បានកើតឡើងតាមលក្ខខណ្ឌដូចខាងក្រោម÷

ក-អត្រា ២០ (ម្ភៃ) រៀលលើមូលដ្ឋាននៃទឹកប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល។ ក្នុងករណីនេះ កម្រៃសេវាត្រូវកំណត់យកលើមូលដ្ឋានសមតុល្យប្រចាំថ្ងៃ ដែលបង្ហាញជូននៅក្នុងសៀវភៅគណនីមូលបត្រ។ កម្រៃនេះមិនត្រូវលើសពី ១២០.០០០ (មួយរយម្ភៃពាន់) រៀល ក្នុងមួយថ្ងៃឡើយ។

ខ-អ្នកត្រូវបង់ប្រាក់ជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។

២-កម្រៃសេវាផ្ទេរមូលបត្ររវាងគណនី (Book Entry Fee):

ក-អត្រាប្រាក់កម្រៃនៃការផ្ទេរមូលបត្ររវាងគណនី ត្រូវគណនាលើមូលដ្ឋានទឹកប្រាក់នៃការជួញដូរដែលបានទូទាត់តាមអត្រា ១០/១០.០០០ (ដប់ភាគមួយម៉ឺន) ចំពោះមូលបត្រកម្មសិទ្ធិ ហើយទឹកប្រាក់កម្រៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។

ខ-អ្នកត្រូវបង់ប្រាក់ជាក្រុមហ៊ុនមូលបត្រជាសមាជិក។

គ-ពេលវេលាបង់ប្រាក់នៅម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់។

៣-កម្រៃប្រតិបត្តិការផ្សេងៗ :

ក-ប្រាក់កម្រៃនៃការផ្ទេរមូលបត្រដែលមិនត្រូវបានជួញដូរ គឺ ១០០.០០០ (មួយរយពាន់) រៀល ក្នុងមួយប្រតិបត្តិការ។ សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃនេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក. នៅពេលស្នើសុំផ្ទេរមូលបត្រ។

ខ-កម្រៃនៃការដកមូលបត្រគឺ ២០០.០០០(ពីររយពាន់) រៀល ក្នុងមួយប្រតិបត្តិការ។ សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃនេះ ជូនប្រតិបត្តិករក្សាទុកមូលបត្រនៃ ផ.ម.ក. នៅពេលស្នើសុំដកមូលបត្រ។

សម្រាប់ឆ្នាំ ២០១៣ អត្រាប្រាក់ថ្លៃសេវានៃការផ្ទេរមូលបត្ររវាងគណនីដូចមានចែងក្នុងកថាខណ្ឌទី ២ ចំណុចទី-២"ក" ខាងលើ ត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន) ចំពោះមូលបត្រកម្មសិទ្ធិ ហើយទឹកប្រាក់កម្រៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។